ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ.....៣៣៤៩.....អពដ

L2022041200527TD2016

ថ្ងៃ សុក្រ ៦ រោច ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ មេសា ឆ្នាំ២០២២

**ជម្រាបមក**

**- លោកប្រធាននាយកដ្ឋានពន្ធលើទ្រព្យ និងអចលនទ្រព្យ**

**- លោកប្រធានសាខាពន្ធដារខេត្តទាំងអស់**

**កម្មវត្ថុ ÷** អំពីការបន្តការលើកលែងពន្ធប្រថាប់ត្រាចំពោះអចលនទ្រព្យដែលមានតម្លៃស្មើ ឬទាបជាង ៧០ ០០០ (ចិតសិបពាន់) ដុល្លារអាមេរិក ដើម្បីជួយសម្រាលបន្ទុកអ្នកជាប់ពន្ធ និងវិស័យអចលនទ្រព្យ ដល់ចំណាច់ឆ្នាំ២០២២។

**យោង ÷** - សេចក្ដីសម្រេចលេខ ១២២ សសរ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល ស្ដីពីការដាក់ឱ្យប្រើប្រាស់នូវក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣

- ចំណារដ៏ខ្ពង់ខ្ពស់ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០២២ របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា លើលិខិតលេខ ២៣៣២ សហវ.អពដ ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- សេចក្ដីណែនាំលេខ ០០២ សហវ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងការអនុវត្តការសម្រេចរបស់រាជរដ្ឋាភិបាល ស្ដីពីវិធានការសម្រួលផ្នែកពន្ធដារ ដើម្បីកាត់បន្ថយផលប៉ះពាល់លើវិស័យសណ្ឋាគារនិងផ្ទះសំណាក់ និងវិស័យអចលនទ្រព្យ។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកប្រធាននាយកដ្ឋាន និងលោកប្រធានសាខាពន្ធដារខេត្ត ជ្រាបថា អនុលោមតាមក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មី សម្រាប់ឆ្នាំ២០២១-២០២៣ របស់រាជរដ្ឋាភិបាល និងផ្អែកតាមចំណារដ៏ខ្ពង់ខ្ពស់របស់សម្ដេចតេជោនាយករដ្ឋមន្ត្រី រាជរដ្ឋាភិបាលសម្រេចបន្តលើកលែងពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ (លំនៅដ្ឋានគ្រប់ប្រភេទ) ដែលមានតម្លៃស្មើ ឬទាបជាង ៧០ ០០០ (ចិតសិបពាន់) ដុល្លារអាមេរិក ដល់ចំណាច់ខែធ្នូ ឆ្នាំ២០២២ តាមលក្ខខណ្ឌនានាកំណត់ក្នុងសេចក្ដីណែនាំអនុវត្តលេខ ០០២ សហវ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចខាងក្រោម ÷

១. ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យដែលមានតម្លៃស្មើ ឬទាបជាង ៧០ ០០០ (ចិតសិបពាន់) ដុល្លារអាមេរិក តាមតម្លៃទីផ្សារជាក់ស្ដែងដែលមានចែងនៅក្នុងកិច្ចសន្យាទិញ-លក់ ចាប់ពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ និងមកធ្វើការប្រកាសបង់ពន្ធប្រថាប់ត្រានៅក្នុងអំឡុងពេលនេះ។

អាគារលេខ មហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ផ្លូវលេខ (២៨៤) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

Scanned with CamScanner

L20220412005J7TD2016

២. ការទទួលកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ (លំនៅឋានគ្រប់ប្រភេទ) ពីក្រុមហ៊ុនអភិវឌ្ឍន៍លំនៅឋាន ដែលបានចុះបញ្ជីនៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ កន្លងមក ឬបច្ចុប្បន្ននៅនិយ័តករអាជីវកម្មអចលនវត្ថុនិងបញ្ចាំ ឬនៅតាមមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៣. ក្រុមហ៊ុនអភិវឌ្ឍន៍លំនៅឋានទាំងអស់ ត្រូវធ្វើកិច្ចសន្យាទិញ-លក់ឱ្យបានត្រឹមត្រូវ ដោយផ្អែកលើតម្លៃទីផ្សារជាក់ស្តែង។ ក្នុងករណីចាំបាច់ អគ្គនាយកដ្ឋានពន្ធដារអាចនឹងធ្វើការត្រួតពិនិត្យឡើងវិញចំពោះក្រុមហ៊ុនអភិវឌ្ឍន៍លំនៅឋានដែលបានឆ្លៀតឱកាសបន្ទាបតម្លៃទិញលក់ ខុសពីទីផ្សារជាក់ស្តែង ធ្វើឱ្យប៉ះពាល់ដល់ចំណូលពន្ធដារ។

ការលើកលែងពន្ធប្រថាប់ត្រានេះ ពុំមានអានុភាពប្រតិសកម្មចំពោះប្រាក់ពន្ធដែលបានបង់រួចហើយនោះទេ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធាននាយកដ្ឋាន និងលោកប្រធានសាខាពន្ធដារខេត្ត ជ្រាប និងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម លោកប្រធាននាយកដ្ឋានពន្ធចលនទ្រព្យនិងអចលនទ្រព្យ និងលោកប្រធានសាខាពន្ធដារខេត្តទាំងអស់ ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅ ពីខ្ញុំ។

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី
ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋាន
ពន្ធដារ

គង់ វិបុល

ចម្លងជូន ៖
- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក
- លោក-លោកស្រីអគ្គនាយករង
- នាយកដ្ឋានរដ្ឋបាល និងកិច្ចការទូទៅ
- នាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ
- ឯកសារ កាលប្បវត្តិ

Scanned with CamScanner